# ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/១១១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រាមួយ:** ត្រូវបានកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និង មាត្រា២០នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា ដូចតទៅ :

**មាត្រា៤ថ្មី :** រាជបណ្ឌិតសភាកម្ពុជា មានសមាជិកបណ្ឌិតសភា បីប្រភេទ :

១. **សមាជិកពេញសិទ្ធិ** ត្រូវជ្រើសរើសតាមការបោះឆ្នោតសម្ងាត់ ក្នុងចំណោមសមាជិកបម្រុង នៃរាជបណ្ឌិតសភាកម្ពុជា ដែលកំពុងបំពេញភារកិច្ច ។ សមាជិកពេញសិទ្ធិអាចមានពី ៤០ ទៅ ៧០នាក់។

២- **សមាជិកបម្រុង** ត្រូវជ្រើសរើសតាមការបោះឆ្នោតសម្ងាត់ដោយសមាជិកពេញសិទ្ធិ ពីក្នុងចំណោមអ្នកមានសញ្ញាបត្របណ្ឌិត ដែលបានដាក់ពាក្យសុំចូល ។

៣- **សមាជិកសមាគមិក** និង**សមាជិកកិត្តិយស** ត្រូវជ្រើសរើសតាមការបោះឆ្នោតសម្ងាត់ដោយសមាជិកពេញសិទ្ធិ ពីក្នុងចំណោមជនជាតិខ្មែរ និងជនបរទេសដែលរស់នៅក្នុង ឬក្រៅប្រទេសកម្ពុជា ហើយដែលបានជួយឧបត្ថម្ភចំពោះការពង្រីកវប្បធម៌ និងវិទ្យាសាស្ត្រជាគុណប្រយោជន៍ ដល់ប្រទេសកម្ពុជា ។

**មាត្រា១០ថ្មី :** រាជបណ្ឌិតសភាកម្ពុជា ត្រូវគ្រប់គ្រងផ្ទាល់ដោយគណៈកម្មាធិការប្រតិបត្តិមួយ ដែលដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួន និងអគ្គលេខាធិការជាជំនួយការ ។ ភារកិច្ចរបស់ប្រធាន អនុប្រធាន និងអគ្គលេខាធិការនៃគណៈកម្មាធិការប្រតិបត្តិនៃរាជបណ្ឌិតសភាកម្ពុជា ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេស ។

**មាត្រា១១ថ្មី :** ប្រធាន អនុប្រធាន និងអគ្គលេខាធិការនៃគណៈកម្មាធិការប្រតិបត្តិនៃរាជបណ្ឌិតសភាកម្ពុជា ត្រូវតែងតាំងដោយ ព្រះរាជក្រឹត្យ ។

**មាត្រា១២ថ្មី :** ប្រធាន អនុប្រធាន និងអគ្គលេខាធិការនៃគណៈកម្មាធិការប្រតិបត្តិនៃរាជបណ្ឌិតសភាកម្ពុជា ត្រូវជ្រើសរើសដោយ សមាជិកពេញសិទ្ធិនៃរាជបណ្ឌិតសភាកម្ពុជា តាមរយៈការបោះឆ្នោតសម្ងាត់ សម្រាប់អាណត្តិ៥ឆ្នាំ ។

**មាត្រា១៤ថ្មី :** ក្នុងករណីដែលប្រធានអវត្តមាន អនុប្រធានមួយរូបនៃរាជបណ្ឌិតសភាកម្ពុជា ត្រូវចាត់តាំងដោយប្រធានឱ្យដឹកនាំការងារជំនួស ។

**មាត្រា១៧ថ្មី :** មហាសន្និបាតវិសាមញ្ញ ត្រូវកោះប្រជុំ ៥ ឆ្នាំម្តង ដើម្បីជ្រើសរើសប្រធាន អនុប្រធាន និងអគ្គលេខាធិការនៃគណៈកម្មាធិការប្រតិបត្តិសម្រាប់អាណត្តិថ្មី ។ ក្នុងករណីដែលមហាសន្និបាតសាមញ្ញ និងវិសាមញ្ញជាន់ឆ្នាំគ្នា មហាសន្និបាតត្រូវប្រព្រឹត្តទៅតែមួយលើក ដោយបញ្ចូលរបៀបវារៈរួមគ្នា ។

**មាត្រា២០ថ្មី :** រាជបណ្ឌិតសភាកម្ពុជា មានវិទ្យាស្ថានឧបសម្ព័ន្ធ ដូចខាងក្រោមនេះ :

*១-វិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ*

ក.ផ្នែកវប្បធម៌វិទ្យា

ខ.ផ្នែកសិល្បៈ និងឥស្សរិយយស

3/5

គ.ផ្នែកស្ថាបត្យកម្ម

ឃ.ផ្នែកបុរាណវិទ្យា

ង.ផ្នែកសិល្បៈទស្សនីយភាព

*២-វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម*

ក.ផ្នែកធម្មសាស្ត្រ និងចរិយាសាស្ត្រ

ខ.ផ្នែកនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

គ.ផ្នែកពាណិជ្ជសាស្ត្រ និងការគ្រប់គ្រង

ឃ.ផ្នែកភូមិវិទ្យា និងនគរូបនីយកម្ម

ង. ផ្នែកប្រវត្តិវិទ្យា និងវិទ្យាសាស្ត្រនយោបាយ

ច.ផ្នែកទស្សនវិជ្ជា និងសង្គមវិជ្ជា

ឆ.ផ្នែកនរវិទ្យា និងជាតិពន្ធុវិទ្យា

ជ.ផ្នែកវិទ្យាសាស្ត្រអប់រំ

*៣-វិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម*

ក.ផ្នែកបរិស្ថានធម្មជាតិ និងជីវវិទ្យា

ខ.ផ្នែកវេជ្ជសាស្ត្រ ទន្តសាស្ត្រ និងឱសថសាស្ត្រ

គ.ផ្នែកកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឃ.ផ្នែកធនធានទឹក

*៤-វិទ្យាស្ថានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា*

ក.ផ្នែកគណិតវិទ្យា និងស្ថិតិ

ខ.ផ្នែកគីមី និងចំណីអាហារ

គ.ផ្នែករូបវិទ្យា និងថាមពល

ឃ.ផ្នែកបច្ចេកវិទ្យា

ង.ផ្នែកព័ត៌មានវិទ្យា និងទូរគមនាគមន៍

*៥-វិទ្យាស្ថានភាសាជាតិ*

ក.ផ្នែកខេមរនីយកម្ម វចនានុក្រម និងបកប្រែ

ខ.ផ្នែកភាសា និងភាសាវិទ្យា

គ.ផ្នែកអក្សរសាស្ត្រ និងអក្សរសិល្ប៍

ឃ.ផ្នែកសិលាចារឹកវិទ្យា

*៦-វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិ*

ក.ផ្នែកទំនាក់ទំនងការទូត

ខ.ផ្នែកទំនាក់ទំនងវប្បធម៌ អប់រំ និងទេសចរណ៍

គ.ផ្នែកទំនាក់ទំនងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឃ.ផ្នែកទំនាក់ទំនងនយោបាយ និងសន្តិសុខ

ង.ផ្នែកទំនាក់ទំនងកសិកម្ម បរិស្ថាន និងថាមពល

ច.ផ្នែកទំនាក់ទំនងសង្គមកិច្ច និងសុខាភិបាល

រាជបណ្ឌិតសភាកម្ពុជា អាចបង្កើតវិទ្យាស្ថានឧបសម្ព័ន្ធផ្សេងទៀត ដោយអនុក្រឹត្យ តាមតម្រូវការចាំបាច់ ។

**មាត្រាពីរ** : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រាបី** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៥០៣.១១៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៥

លេខ: ១០៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ ៣ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង តាន់

5/5